ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ........សហវ .វស

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៤.៩៨៧.៦១៣.៤០ដុល្លារអាមេរិក សម្រាប់ការងារជួសជុលនូវប្រព័ន្ធប្រឡាយមេភ្នំដីព្រៃមាន់។

**យោង:** លិខិតលេខ ១៤៦១ ធទឧ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ៤.000.000 ដុល្លារអាមេរិក (បួនលានដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ការងារជួសជុលនូវប្រព័ន្ធប្រឡាយមេភ្នំដីព្រៃមាន់ ស្ថិតក្នុងស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2480-CAM(SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com